# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១៣ . សសរ**

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារថ្នាក់ជាតិ ដើម្បីអនុវត្តកិច្ចព្រមព្រៀង អនុស្សរណៈនៃការយោគយល់គ្នា រវាងរាជរដ្ឋាភិបាលកម្ពុជា និងបណ្តាប្រទេសពាក់ពន្ធ័ស្តីពីការលុបបំបាត់អំពើជួញដូរមនុស្ស និងជួយជនរងគ្រោះដោយសារការជួញដូរ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១០៥ / ០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងប្រឆាំងនឹងនារីភេទ ដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខានៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ១៩៩២ និងបានផ្តល់សច្ចាប័ននៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២
- បានឃើញអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខានៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩២ និងបានផ្តល់សច្ចាប័ននៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២
- បានឃើញព្រះរាជក្រមលេខ នស / រកម / ១០០៥ / ០៣២ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាអង្គការអន្តរជាតិខាងការងារលេខ ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់ ដើម្បីលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុត នៃពលកម្មកុមារ
- បានឃើញព្រះរាជក្រមលេខ នស / រកម /០១០៦ / ០០៤ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃពិធីសារស្តីពីការទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ដែលបំពេញបន្ថែមលើអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីការប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែន ដែលមានអង្គការចាត់តាំង
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

## ស ម្រេ ច

**ប្រការ ១** : បង្កើតក្រុមការងារថ្នាក់ជាតិ ដើម្បីអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី អនុស្សរណៈ នៃការយោគយល់គ្នា រវាងរាជរដ្ឋាភិបាលកម្ពុជា និងបណ្តាប្រទេសពាក់ព័ន្ធ ស្តីពីការលុបបំបាត់ការជួញដូរមនុស្ស និងជួយជនរងគ្រោះ ដោយសារការជួញដូរ ហៅកាត់ថា ក.អ.ល.ជ។

**ប្រការ ២** : **ក.អ.ល.ជ** មានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១- រដ្ឋលេខាធិការក្រសួងកិច្ចការនារី | ០១រូប | ប្រធាន |
| ២- អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ០១រូប | អនុប្រធាន |
| ៣- អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ០១រូប | អនុប្រធាន |
| ៤- អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា | ០១រូប | អនុប្រធាន |
| ៥- អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ០១រូប | អនុប្រធាន |
| ៦- តំណាងក្រសួងកិច្ចការនារី | ០១រូប | សមាជិកអចិន្ត្រៃយ៍ |
| ៧- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ០១រូប | សមាជិក |
| ៨- តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ០១រូប | សមាជិក |
| ៩- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១រូប | សមាជិក |
| ១០- តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ០១រូប | សមាជិក |
| ១១- តំណាងក្រសួងទេសចរណ៍ | ០១រូប | សមាជិក |
| ១២- តំណាងក្រសួងអប់រំ យុវជន និងកីឡា | ០១រូប | សមាជិក |
| ១៣-តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ០១រូប | សមាជិក |
| ១៤- តំណាងក្រសួងព័ត៌មាន | ០១រូប | សមាជិក |
| ១៥- តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ | ០១រូប | សមាជិក |
| ១៦- តំណាងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស | ០១រូប | សមាជិក |
| ១៧- តំណាងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី | ០១រូប | សមាជិក |
| ១៨- តំណាងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | ០១រូប | សមាជិក |

ការតែងតាំងប្រធាន អនុប្រធាន និងសមាជិក **ក.អ.ល.ជ** ខាងលើនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**ប្រការ ៣** : **ក.អ.ល.ជ** ជាសេនាធិការរបស់រាជរដ្ឋាភិបាល ដែលមានភារកិច្ចដូចខាងក្រោម :

- ជួយរាជរដ្ឋាភិបាល ក្នុងការអនុវត្តកិច្ចព្រមព្រៀងកម្ពុជា-វៀតណាម អនុស្សរណៈនៃការយោគយល់គ្នាកម្ពុជា-ថៃ អនុស្សរណៈនៃការយោគយល់គ្នាថ្នាក់មហាអនុតំបន់មេគង្គ និងកិច្ចព្រមព្រៀងជាមួយបណ្តាប្រទេសពាក់ព័ន្ធស្តីពីការលុបបំបាត់ការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ និងជួយដល់ជនរងគ្រោះដោយសារការជួញដូរ
- រៀបចំផែនការសកម្មភាពទ្វេភាគី និងថ្នាក់មហាអនុតំបន់ ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ពិសេសការជួញដូរស្ត្រី និងកុមារ ដោយប្រមូលផ្តុំនូវកិច្ចខិតខំប្រឹងប្រែងចាំបាច់នានា ដើម្បីប្រែក្លាយផែនការសកម្មភាពនេះ ឱ្យទៅជាការអនុវត្តជាក់ស្តែង
- ជំរុញការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី និងផ្នែកផ្សេងៗទៀតស្តីពី កិច្ចសហប្រតិបត្តិការប្រឆាំងការជួញដូរមនុស្ស[illegible] និងការងារគ្រប់រូបភាព

- ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី និងថ្នាក់អនុតំបន់ស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្ស និងធ្វើរបាយការណ៍ជូនគណៈកម្មការរួម នៃកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគី ក្នុងកិច្ចប្រជុំប្រចាំឆ្នាំ
- ពិនិត្យឡើងវិញនូវការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី និងថ្នាក់អនុតំបន់ស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្សរៀងរាល់ ២ ឬ ៣ ឆ្នាំម្តង ហើយរាយការណ៍ជូនរាជរដ្ឋាភិបាល
- សហការជាមួយលេខាធិការដ្ឋានរបស់គម្រោងអន្តរភ្នាក់ងារសហប្រជាជាតិ ស្តីពីការជួញដូរមនុស្សនៅក្នុងមហាអនុតំបន់មេគង្គប្រចាំកម្ពុជា ប្រចាំអនុតំបន់ និងជាមួយក្រុមការងារបណ្តាប្រទេសដៃគូដទៃទៀត ក្នុងការសម្របសម្រួលរាល់សកម្មភាពថ្នាក់ជាតិ សកម្មភាពរួម និងថ្នាក់តំបន់ និងសហការ ព្រមទាំងសម្របសម្រួលជាមួយក្រុមការងារ ដែលពាក់ព័ន្ធនឹងបញ្ហាទេសន្តរប្រវេសន៍
- ស្នើសុំជំនួយផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ និងអ្នកជំនាញការអន្តរជាតិ តាមការចាំបាច់ ដើម្បីជួយបណ្តុះបណ្តាល និងជួយតាមដានវាយតម្លៃការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី និងថ្នាក់អនុតំបន់នានា
- ចូលរួមក្នុងការរៀបចំរបាយការណ៍ជាតិស្តីពីការប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា មុននឹងបញ្ជូនទៅអង្គការសហប្រជាជាតិ
- ចូលរួមក្នុងការរៀបចំផែនការសកម្មភាពថ្នាក់ជាតិ ៥ ឆ្នាំស្តីពីការប្រឆាំងការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ មុននឹងសុំការអនុម័តពីរាជរដ្ឋាភិបាល ដោយមានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារជាអ្នកសម្របសម្រួល ។

**ប្រការ ៤ :** គ.អ.ល.ជ ពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី និងថ្នាក់អនុតំបន់ ជាមួយអង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ ក្នុងការកៀរគរជំនួយ ដើម្បីអនុវត្តផែនការសកម្មភាពទាក់ទងនឹងការជួញដូរមនុស្ស ។
គ.អ.ល.ជ មានថវិកាផ្ទាល់ខ្លួន ដែលជាតារាងឧបសម្ព័ន្ធរបស់ក្រសួងកិច្ចការនារី និងថវិកាជំនួយឧបត្ថម្ភពីអង្គការអន្តរជាតិ ប្រទេសផ្តល់ជំនួយ និងសប្បុរសជនជាតិ និងអន្តរជាតិ ។

**ប្រការ ៥ :** សមាជិក គ.អ.ល.ជ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។ ប្រធាន គ.អ.ល.ជ អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន និងបុគ្គលផ្ទាល់ ដែលមានការពាក់ព័ន្ធចូលរួមប្រជុំបាន ។ ក្នុងករណីចាំបាច់ គ.អ.ល.ជ ត្រូវរាយការណ៍ពីលទ្ធផល និងពីសំណូមពររបស់អង្គប្រជុំជូនរាជរដ្ឋាភិបាល ដើម្បីស្នើសុំគោលការណ៍សម្រេច ។

**ប្រការ ៦ :** គ.អ.ល.ជ អាចបង្កើតក្រុមការងារសម្របសម្រួលអន្តរក្រសួង តាមការចាំបាច់ជាជំនួយការ ក្នុងកិច្ចសហការសម្របសម្រួលភារកិច្ចរបស់ខ្លួន ដូចមានចែងក្នុងប្រការ ២ នៃសេចក្តីសម្រេចនេះ ។ សមាសភាព តួនាទី និងភារកិច្ចរបស់ក្រុមការងារនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.អ.ល.ជ ។

**ប្រការ ៧ :** គ.អ.ល.ជ មានលេខាធិការដ្ឋានអចិន្ត្រៃយ៍ ដែលមានទីតាំងស្ថិតនៅទីស្តីការក្រសួងកិច្ចការនារី ដោយប្រើប្រាស់មន្ត្រីមានក្របខ័ណ្ឌស្រាប់ ដើម្បីជាជំនួយការក្នុងកិច្ចសហការសម្របសម្រួលការងារ ដែលពាក់ព័ន្ធនឹងបញ្ហាជួញដូរមនុស្ស និងកិច្ចការជួយជនរងគ្រោះដោយសារអំពើជួញដូរ ។
តួនាទី និងភារកិច្ចរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.អ.ល.ជ ។
គ.អ.ល.ជ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងកិច្ចការនារី ។

**ប្រការ ៨ :** គ.អ.ល.ជ សម្របសម្រួលការងារជាមួយក្រុមការងារចម្រុះថ្នាក់ខេត្ត-ក្រុង ដែលបានបង្កើតរួច ហើយត្រូវរក្សាទុកដើម្បីកិច្ចសហការសម្របសម្រួលភារកិច្ចរបស់ខ្លួន ដូចមានចែងក្នុងប្រការ ៣ នៃសេចក្តីសម្រេចនេះ ។ ចំពោះ

ខេត្ត-ក្រុង ដែលមិនទាន់បានបង្កើត ត្រូវបង្កើតក្រុមការងារចម្រុះថ្នាក់ខេត្ត-ក្រុង ដឹកនាំដោយអភិបាលរងខេត្ត-ក្រុង និងមានសមាជិក មកពីមន្ទីរពាក់ព័ន្ធនឹងប្រការ ២ នៃសេចក្តីសម្រេចនេះ លើកលែងតែស្ថាប័នណា ដែលមិនមានអង្គភាពចំណុះ តាមបណ្តាខេត្ត-ក្រុង។

ក្រុមការងារចម្រុះខេត្ត-ក្រុង មានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្ត-ក្រុង។

**ប្រការ ៩** : សេចក្តីសម្រេចលេខ ៤០ សសរ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិ ដើម្បីអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រថៃ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរកុមារ និងស្ត្រី និងជួយដល់ជនរងគ្រោះដោយសារការជួញដូរ និងសេចក្តីសម្រេចលេខ ២៥ សសរ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៦ ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីអនុវត្តកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរស្ត្រី និងកុមារ និងជួយដល់ជនរងគ្រោះដោយសារការជួញដូរ និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១០**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត-ក្រុង និងបណ្តាសមាសភាព ដែលមានចែងក្នុងប្រការ ២ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ១០*
- *ឯកសារ-កាលប្បវត្តិ*